


# គំនិត រឹម និង សំខាន់

Une idée marginale et fondamentale

គំនិត ចង់បង្កើត នូវរដ្ឋាភិបាលនិរទេស ដែលជាគំនិតកើតចេញពីទ្រឹស្តី របស់បថុជ្ជន (théorie des gens) ហើយវាកំពុងទូទ័រ នៅក្នុងមជ្ឈដ្ឋាន នៃពួកអ្នកនយោបាយ ប្រឆាំងនឹងរបបភ្នំពេញ ពង្រា នូវការពិភាក្សា ទៅលើបញ្ហាសំខាន់មួយចំនួន ដូចយ៉ាង :

- ស្ថានភាព នៃរដ្ឋាភិបាលនិរទេស ធៀបនឹង កិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ ;
- ស្ថានភាព នៃរដ្ឋាភិបាលនិរទេស ធៀបនឹង រដ្ឋធម្មនុញ្ញជាធរមាន ;
- គោលជំហរ នៃរដ្ឋាភិបាលនិរទេស នៅចំពោះមុខ ព្រះមហាក្សត្រ ;
- ទីតាំង នៃរដ្ឋាភិបាលនិរទេស នៅក្នុងប្រទេសមហាអំណាចមួយ ដែលប្រទេសនោះ គេទទួលស្គាល់ នៃអត្តាភាពខ្លួន ;
- មធ្យោបាយគ្រប់បែបយ៉ាង ដើម្បី ធ្វើអោយ រដ្ឋាភិបាលអាចប្រព្រឹត្តិទៅបានដោយសក្តិសិទ្ធ ;

- អ្នកណាជាអ្នកផ្តើមគំនិត ? អ្នកដឹកនាំគណៈបក្សសង្គ្រោះជាតិ ? វរជនខ្មែរដ៏ឆ្នើមណាមួយ ដែលអាចបង្រួបបង្រួមខ្មែរគ្រប់មជ្ឈដ្ឋានបាន ?

បើជាគំនិតរឹម គឺគួរអោយចង់សោច តែបើជាគំនិតសំខាន់ គឺគួរបារម្ភជាទីបំផុត សំរាប់ប្រជាជាតិខ្មែរ ព្រោះជួនកាល វាបែរជាបង្កើតបញ្ហាបន្ថែម តែប៉ុណ្ណោះ។ ការពិត របស់ប្រជាជាតិខ្មែរ វាមានតែមួយគត់ គឺ **ប្រជាពលរដ្ឋខ្មែរ** បើគាត់មិនកម្រើក គឺគ្មានព្រះបាទធម្មិកមកពីឋានណា អាចជួយគាត់បាននោះឡើយ៕